ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៣០
ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩
-សំណុំរឿងជំនុំជម្រះលេខៈ ៦៨៤
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩
-សាលក្រមព្រហ្មទណ្ឌលេខៈ **១០៦ "ខ"**
ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង ខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈនៅនាទីសាលាដំបូងខេត្តសៀមរាប
សាលសវនាការលេខ២B នាថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសសាលក្រមជាសាធារណៈ
នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩។

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ជាចៅក្រមប្រឹក្សាជំនុំជម្រះ
លោក ជាចៅក្រមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខៈ ៤៣០ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ហឹត់ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៥ថ្មី មុខរបរ អ្នកបើកបរ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅ[redacted] ខេត្តសៀមរាប នៅលីវ ឪពុកឈ្មោះ [redacted] ស៊ីណាត (រ) ម្តាយឈ្មោះ [redacted] សុទី (រ) ទោសពីមុនគ្មាន។(ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៥២៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

២-ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៧ថ្មី មុខរបរ កម្មករ ទីកន្លែងកំណើតនៅ[redacted] ខេត្តសៀមរាប

Scanned with CamScanner

ឈ្មោះ[redacted] ខាន មានកូន០១នាក់ ឪពុកឈ្មោះ [redacted] វណ្ណា (រ) ម្តាយឈ្មោះ [redacted] ទ្រព្យ (រ) ទោសពីមុនគ្មាន។(ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៥២៧ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

៣-ឈ្មោះ [redacted] ទីទី ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ ថ្នាក់ទី៧ថ្មី មុខរបរ សន្តិសុខ ទីកន្លែងកំណើត[redacted] ខេត្តសៀមរាប មានទីលំនៅមុនពេលចាប់ខ្លួននៅភូមិបឹង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នៅលីវ ឪពុកឈ្មោះ [redacted] សុគុន (រ) ម្តាយឈ្មោះ [redacted] ភារ៉ែ (រ) ទោសពីមុនគ្មាន។(ក្នុងឃុំ)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខៈ ៥២៨ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩។

ត្រូវជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣-៤ **នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ត់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] **ទីទី។**

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៥៥៣ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៣៤៩៦ ពស.ព្រស ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១០៧១ ពស.ព្រជ (ក) ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៩ របស់លោកប្រធានសាលាដំបូងខេត្តសៀមរាប។

**ឯអង្គហេតុកើតមានឡើងដូចតទៅៈ**

កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ កម្លាំងសមត្ថកិច្ចបានចុះបង្ក្រាបបទល្មើសចែកចាយគ្រឿងញៀនជាក់ស្តែង មានទីតាំងស្ថិតនៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ដោយបានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ហ៊ត់ ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ ដោយបានធ្វើការដកហូតថ្នាំញៀនចំនួន ០១កញ្ចប់ ទម្ងន់ ០,២២ក្រាម និងបានពិនិត្យទឹកនោមរកសារធាតុញៀន លទ្ធផលវិជ្ជមាន។ បន្ទាប់មក សមត្ថកិច្ចបានបន្តធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ទីទី ភេទប្រុស អាយុ១៥ឆ្នាំ ជាអ្នកលក់ថ្នាំញៀន និងបានដកហូតថ្នាំញៀនចំនួន ០៣កញ្ចប់ ទម្ងន់ ០,៨៥ក្រាម ស្ថិតនៅចំណុចភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប និងបានធ្វើការពិនិត្យទឹកនោមរកសារធាតុញៀន លទ្ធផលវិជ្ជមាន។

តំណាងអយ្យការនាពេលសវនាការ បានធ្វើសេចក្ដីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការ តាមរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ស្នើសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ: ៣៦៥ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

លោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] ហ៊ិត់ បានធ្វើសេចក្ដីសន្និដ្ឋានថា: ឆ្លងតាមសវនាការ និងភស្តុតាងកន្លងមក និងតាមចម្លើយពេលសវនាការឃើញថាកូនក្ដីខ្លួនមិនបានប្រព្រឹត្តបទល្មើសជួញដូរនោះទេ ព្រោះកូនក្ដីខ្លួនមិនដឹងរឿងទទួលថ្នាំអ្វីឡើយ ហើយកូនក្ដីខ្លួនក៏មិនបានទទួលផលពីរឿងជួញដូរថ្នាំញៀនដែរ។ ហេតុនេះស្នើសុំលោកតុលាការពិចារណាឲ្យកូនក្ដីខ្លួនរួចផុតពីការចោទប្រកាន់។

លោក [redacted] ជាមេធាវីការពារសិទ្ធិអោយជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីខ្លួនបានសារភាពថាបានជួយយកថ្នាំញៀនឲ្យគេ បានផលចំនួន ០១ម៉ឺនរៀល ដោយសារកូនក្ដីខ្លួននៅក្មេង ខ្វះការយល់ដឹង ឆាប់ជឿគេ ម្យ៉ាងទៀតកូនក្ដីខ្លួនមានប្រពន្ធកូនក្នុងបន្ទុក ស្នើសុំលោកតុលាការដាក់ទោសអប្បបរមា និងអនុវត្តទោសចំពោះអនីតិជន។ ចំពោះឈ្មោះ [redacted] ទីទី បានសារភាពខ្លួនពិតជាបានប្រព្រឹត្ត ហេតុនេះស្នើសុំលោកតុលាការអនុវត្តទោសអប្បបរមា និងយកច្បាប់អនីតិជនមកប្រើ។

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ិត់ ។

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ។

-បានស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ទីទី ។

-បានពិនិត្យភស្តុតាងនានា។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ។

**ក្រោយពីបានពិនិត្យ ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ÷**

**សំអាងហេតុ**

-ក្រោយពីពិនិត្យភស្តុតាង និងផ្ទៀងផ្ទាត់ចម្លើយជនជាប់ចោទ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ហ៊ិត់ ,ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ទីទី ពិតជាបានប្រព្រឹត្តបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ ស្ថិតនៅចំណុចភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ប្រាកដមែន។ ដោយជនជាប់ចោទខាងលើ បានយកថ្នាំញៀនទៅលក់ឲ្យគេ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។

-ជនជាប់ចោទឈ្មោះ [redacted] ហ៊ិត់ ,ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ទីទី ជាអនីតិជន តែជនទាំងនេះមានសមត្ថភាព ,ស្មារតី និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវទង្វើ

វដែលខ្លួនបានប្រព្រឹត្ត ដូចការចោទប្រកាន់បញ្ជូនមកជម្រះរបស់ចៅក្រមស៊ើបសួរ តាមដីកាដំណោះស្រាយលេខ: ៣៤៩៦ ពស.ព្រស ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩។

-តាមភស្តុតាង និងការពិនិត្យលើកិច្ចស៊ើបសួរពីមន្ត្រីនគរបាលយុត្តិធម៌ រហូតដល់ជម្រះ ឃើញថាជនខាងលើពិតជាមានចេតនាក្នុងការប្រព្រឹត្តបទល្មើសនោះយ៉ាងពិតប្រាកដមែន តាមមាត្រា០៤ នៃក្រមព្រហ្មទណ្ឌ។

-តាមការពិនិត្យលើអង្គហេតុខាងលើនេះ និងសាវតាជាតិរបស់ឈ្មោះ[redacted] ហ៊ត់ ភេទប្រុស អាយុ១៦ឆ្នាំ ,ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ[redacted] ទីទី ភេទប្រុស អាយុ១៥ឆ្នាំ ជាអនីតិជន ដូចនេះគប្បីពិនិត្យលើការបន្ថយទោសនៅត្រឹមពាក់កណ្តាល នៃមូលទោស តាមមាត្រា ១៦០ និងមាត្រា១៦៤ នៃក្រមព្រហ្មទណ្ឌ។

-ដោយយោងតាមសាវតាជាតិរបស់ជនជាប់ចោទខាងលើ ឃើញថាជាអនីតិជន មានស្ថានភាពជីវភាពក្រីក្រ គប្បីអនុវត្តតាមមាត្រា ៩៧ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌ មិនពិន័យជាប្រាក់ចំពោះជនជាប់ចោទ។

-ចំពោះវត្ថុតាងរួមមាន ទូរស័ព្ទដៃម៉ាក Iphone5 IMEI: 990002268571914 ពណ៌ស មានស៊ីម Smart ចំនួន០១គ្រឿង ,ទូរស័ព្ទដៃម៉ាក camfone មិនស្គាល់Model ពណ៌ខ្មៅលាយលឿង គ្មានស៊ីម ចំនួន០១គ្រឿង និងទូរស័ព្ទដៃម៉ាក i-mobile S/N:20160115050356 ពណ៌ខ្មៅ មានស៊ីម Smart ចំនួន០១គ្រឿង គួរគប្បីសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] ហ៊ត់ ភេទប្រុស អាយុ១៦ឆ្នាំ ,ឈ្មោះ[redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ និងឈ្មោះ[redacted] ទីទី ភេទប្រុស អាយុ១៥ឆ្នាំ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ បទល្មើស ព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៣-៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ហេតុដូច្នេះសម្រេច៖

១-ផ្តន្ទាទោស៖

-ឈ្មោះ [redacted] ហ៊ត់ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ (ដូចមានសាវតាជាតិខាងលើ)

-ឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៧ឆ្នាំ ជាតិខ្មែរ (ដូចមានសាវតាជាតិខាងលើ)

ដាក់ពន្ធនាគារម្នាក់ៗកំណត់ចំនួន ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ។

-ឈ្មោះ[redacted] ទីទី ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ (ដូចមានសាវតាជាតិខាងលើ)

ដាក់ពន្ធនាគារកំណត់ចំនួន ០២ (ពីរ) ឆ្នាំ។



Scanned with CamScanner

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិមណ្ឌល២ សង្កាត់ស្វាយ-ដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌ៣-៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមានៈ

-ទូរស័ព្ទដៃម៉ាក Iphone5 IMEI: 990002268571914 ពណ៌ស មានស៊ីម Smart ចំនួន០១គ្រឿង

-ទូរស័ព្ទដៃម៉ាក camfone មិនស្គាល់Model ពណ៌ខ្មៅលាយលឿង គ្មានស៊ីម ចំនួន ០១គ្រឿង

-ទូរស័ព្ទដៃម៉ាក i-mobile S/N:20160115050356 ពណ៌ខ្មៅ មានស៊ីម Smart ចំនួន ០១គ្រឿង

**ត្រូវរឹបអូស ជាសម្បត្តិរដ្ឋ។**

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ត់ ,ឈ្មោះ [redacted] វណ្ណៈ និងឈ្មោះ [redacted] ទីទី ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខានិងត្រា: [redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

សៀមរាប, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner